ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ
សូមគោរពជូន
លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ានីណេត អគ្គស្នងការ
នៃសហភាពមាយយុទ្ធិនារីកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៦

លោកជំទាវបណ្ឌិត ជាទីគោរពជ្រាលជ្រៅ!

ក្នុងវិកាសដ៏មហាវិសេសវិសាល ពោរពេញដោយសេចក្ដីសោមនស្សរីករាយ **ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៦** ខាងមុខនេះ: តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្រុមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **លោកជំទាវបណ្ឌិត** សូមទទួលបាននូវសុខភាពល្អហឫទ្ធិ កម្លាំងកាយមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយืนយូរ ដើម្បីមានចំណែកជាមួយជនរួមជាតិ ក្នុងការជម្រុញការជម្រះខឿនសេដ្ឋកិច្ចជាតិឲ្យកាន់តែរីកចម្រើន និងអភិវឌ្ឍប្រទេសជាតិ ឲ្យកាន់ចម្រើនរុងរឿងលើគ្រប់វិស័យ។

នាវិកាសដ៏មហាប្រសើរនេះ: យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្ដីគោរពយ៉ាងស្មោះស្ម័គ្ររនិងការកោតសរសើរ ចំពោះ: **លោកជំទាវបណ្ឌិត** ដែលជាកូលពីតាខ្មែរដ៏ឆ្នើមមួយរូបប្រកបដោយទេពកោសល្ស និងសមត្ថភាព តែងឧិតខំប្រឹងប្រែងលះបង់អស់កម្លាំងកាយចិត្ত ក្នុងការបំពេញបេសកកម្មមនុស្សធម៌ ប្រកបដោយគុណធម៌ និងបានរួមចំណែកយ៉ាងធំធេងដល់ការលើកកម្ពស់សីលធម៌សង្គម គាំទ្រក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី និងជាពិសេសក្នុងការដឹកនាំក្រុមត្រួតពិនិត្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ ជម្នះរាល់ការលំបាកជាច្រើនក្នុងសមរភូមិជំងឺកូវីដ-១៩ កន្លងមក និងទទួលបាននូវជោគជ័យធំធេងជូនជាតិមាតុភូមិ។

ជាចុងក្រោយទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុសក្ដិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះប្រាំនូវសព្វសាធុការពរជ័យ ជូន **លោកជំទាវបណ្ឌិត** និង**សម្តេចមហាបវរធិបតី** ព្រមទាំងបុត្រា បុត្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ានីណេត អគ្គស្នងការ នៃសហភាពមាយយុទ្ធិនារីកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ[illegible] ១[illegible]ខែ[illegible]ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៥ នៃ [illegible] ឆ្នាំ២០២៥
ទេសរដ្ឋមន្ត្រី ជ្រមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍ ទៀ សីហា

វិថីហ្សក១ មហាវិត្ថារ សង្កាត់ទន្លេបាសាក ខណ្ឌឫស្សីកែ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២១៦ email: generalsec@mod.gov.kh

លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ានីណេត
អគ្គស្នងការនៃសហភាពមាយយុទ្ធិនារីកម្ពុជា

អរគុណសន្ធិភាព! អរគុណនយោបាយឈ្នះឈ្នះ!